# សេចក្តីប្រកាសព័ត៌មានរួម

*១៦ វិច្ឆិកា ២០២៣*

## សប្តាហ៍ថាមពលស្អាតឆ្នាំ ២០២៣ បើកកម្មវិធីជាមួយនឹងការអំពាវនាវឱ្យមានសកម្មភាពលើអន្តរកាលថាមពលស្អាត

ថ្ងៃនេះកម្ពុជា អូស្ត្រាលី នូវែលសេឡង់ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) បានបើកសម្ពោធសប្តាហ៍ថាមពលស្អាតកម្ពុជាឆ្នាំ ២០២៣ ដោយអំពាវនាវឱ្យមានសកម្មភាពសម្របសម្រួលលើអន្តរកាលថាមពលស្អាតពីគ្រប់ភាគីពាក់ព័ន្ធ។

កម្មវិធីបើកសម្ពោធសប្តាហ៍ថាមពលស្អាត២០២៣នេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ឯកឧត្តម ពៅ ម៉ាលី រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម កាន់ ផារិទ្ធ រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តម ឯក រដ្ឋ អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន។

កម្មវិធីនេះមានសុន្ទរកថាស្វាគមន៍ពីឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា ចាស្ទីន វ៉ាយអេត លោក Matthew Allen លេខាទីមួយ ផ្នែកអភិវឌ្ឍន៍ របស់ស្ថានទូតនូវែលសេឡង់ប្រចាំកម្ពុជា ឡាវ និងថៃ និងលោកស្រី អាលីហ្សា ឆាកឃី អ្នកតំណាង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជា និងលោកណាត្តារុណ ង៉ោ សឺន នាយកប្រចាំប្រទេសរបស់អង្គការអេននឺជីឡេប (EnergyLab Cambodia)

កម្មវិធីនេះក៏មានការចូលរួមពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងៗដែលធ្វើការក្នុងវិស័យថាមពលស្អាត។ ប្រធានបទនៃសប្តាហ៍ថាមពលស្អាតនៅឆ្នាំនេះគឺ «សន្តិសុខថាមពល និងអនាគតថាមពលស្អាតរបស់កម្ពុជា»។

ឯកអគ្គរដ្ឋទូតអូស្ត្រាលី វ៉ាយអេត មានប្រសាសន៍ថា «អន្តរកាលថាមពលស្អាតរបស់កម្ពុជា គឺជាឱកាសមួយដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងនិរន្តរភាព។ អូស្ត្រាលីប្តេជ្ញាគាំទ្រការផ្លាស់ប្តូរនេះ រួមទាំងការចែករំលែកបទពិសោធន៍របស់យើងក្នុងការធ្វើអន្តរការថាមពលកកើតឡើងវិញទៅក្នុងបណ្តាញអគ្គិសនីមេ ដើម្បីជួយកម្ពុជាសម្រេចបាននៅលទ្ធផលតាមការរំពឹងទុក។»

ឯកអគ្គរដ្ឋទូត វ៉ាយអេត បានបន្ថែមថា «តាមរយៈកម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់(CAPRED) អូស្ត្រាលីកំពុងធ្វើការជាមួយក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងភាគីពាក់ព័ន្ធដទៃទៀតលើការរួមបញ្ចូលថាមពលកកើតឡើងវិញ។ CAPRED ក៏កំពុងអនុវត្តគម្រោងដែលជួយឲ្យប្រជាជននៅតំបន់ដាច់ស្រយាលដែលមិនទាន់ត្រូវបានភ្ជាប់ទៅកាន់បណ្តាញអគ្គិសនី ឱ្យមានលទ្ធភាពភ្ជាប់ទៅនឹងបណ្តាញអគ្គិសនីខ្នាតតូចដើរដោយថាមពលសូឡា និងគាំទ្រប្រសិទ្ធភាពថាមពល តាមរយៈទីផ្សារក្រុមហ៊ុនផ្តល់សេវាកម្មថាមពល (ESCOs)។»

លោកស្រី Alissar Chaker អ្នកតំណាង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជាមានប្រសាសន៍ថា «ការទទួលយកថាមពលស្អាតមិនមែនជាគោលជំហរមនោគមវិជ្ជាទេ។ វាគឺជាឱកាសអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់កម្ពុជាក្នុងការបង្កើនសន្តិសុខថាមពល បង្កើតភាគលាភពាណិជ្ជកម្ម និងការងារ លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងបង្កើនភាពធន់ និងបរិយាបន្ន។

«UNDP កំពុងធ្វើការដើម្បីលើកកម្ពស់ និងគាំទ្រដល់អន្តរកាលថាមពលនៅក្នុងប្រទេសកម្ពុជា តាមរយៈភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល បញ្ញវន្ត និងស្ថាប័នឯកជន។ យើងប្តេជ្ញាជំរុញរបៀបវារៈនេះតាមរយៈវិធីសាស្ត្ររួមបញ្ចូលគ្នាដែលផ្តោតលើគោលនយោបាយ ការអនុវត្តរួមគ្នាសម្រាប់ការដាក់ឱ្យប្រើប្រាស់នូវដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត និងបច្ចេកវិទ្យាថាមពលស្អាត ការអភិវឌ្ឍន៍សមត្ថភាព និងហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិត។ ជាឧទាហរណ៍ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយនេះ UNDP បានគាំទ្របទប្បញ្ញត្តិសំខាន់ៗដូចជាការណែនាំអំពីថាមពលសូឡានៅលើដំបូល និងប្រសិទ្ធភាពថាមពលនៅក្នុងអគារ។ យើងបានតភ្ជាប់បណ្តាញអគ្គិសនីដល់ភូមិដែលមិនបានភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋចំនួន ២១ ដែលមានបណ្តាញអគ្គិសនីខ្នាតតូចដើរដោយថាមពលពន្លឺព្រះអាទិត្យ ដោយផ្តល់លទ្ធភាពទៅដល់សហគមន៍ដាច់ស្រយាល និងតំបន់ដែលនៅខ្វះខាតផងដែរ។»

លោក Allen លេខាទីមួយ ផ្នែកអភិវឌ្ឍន៍ នៃស្ថានទូតនូវែលសេឡង់ប្រចាំកម្ពុជា ឡាវ និងថៃ បានមានប្រសាសន៍ថា «នូវែលហ្សេឡង់ សូមស្វាគមន៍ចំពោះឱកាសនានាក្នុងការជួយដល់ប្រទេសកម្ពុជាក្នុងដំណើរអន្តរកាលថាមពលស្អាតនាពេលអនាគត។ ព្រឹត្តិការណ៍ដូចជាសប្តាហ៍ថាមពលស្អាត ផ្តល់ឱកាសដើម្បីបណ្តុះការផ្លាស់ប្តូរជាវិជ្ជមាន និងចែករំលែកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហាបន្ទាន់បំផុតដែលពិភពលោកកំពុងប្រឈមមុខនាពេលបច្ចុប្បន្ននេះ។ តាមរយៈការដឹកនាំ និងការផ្តល់អនុសាសន៍ដល់ភាគីពាក់ព័ន្ធទាំងអស់ ដូចជាអ្នកទាំងអស់គ្នាដែលមានវត្តមានក្នុងកម្មវិធីនេះ ដែលយើងនឹងធ្វើការរួមគ្នាឆ្ពោះទៅរកចក្ខុវិស័យនៃអនាគតពណ៌បៃតង និងនិរន្តរភាព»។

លោកណត្ថារុណ នាយកប្រចាំប្រទេសរបស់អង្គការអេននឺជីឡេប (EnergyLab Cambodia)បានមានប្រសាសន៍ថា «យើងសង្ឃឹមថាសប្តាហ៍ថាមពលស្អាតឆ្នាំ២០២៣ នឹងគាំទ្រដល់គោលដៅមួយរបស់ឯកឧត្តម កែវ រតនៈ ក្នុងការបង្កើនថាមពលកកើតឡើងវិញអថេរ (VRE) និងថាមពលសូឡា ដើម្បីបង្កើនសន្តិសុខថាមពលរបស់កម្ពុជា»។

កម្មវិធីនេះក៏មានកិច្ចពិភាក្សាលើអាទិភាពសំខាន់ៗសម្រាប់អន្តរកាលថាមពលស្អាតរបស់ប្រទេសកម្ពុជា ដោយមានវាគ្មិនកិត្តិយសមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារពិភពលោក កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់(CAPRED) និង Empacte។

សប្តាហ៍ថាមពលស្អាតឆ្នាំ២០២៣ ត្រូវបានរៀបចំឡើងដោយ អង្គការអេននឺជីឡេប (EnergyLab Cambodia) ក្នុងភាពជាដៃគូ និងសហប្រតិបត្តិការជាមួយនឹងសហស្ថាបនិករួមមាន រដ្ឋាភិបាលអូស្ត្រាលី និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងទទួលបានមូលនិធិពីអូស្ត្រាលីតាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់(CAPRED) ក្រសួងការបរទេស និងពាណិជ្ជកម្មនូវែលសេឡង់ និងគម្រោងកម្មវិធីផ្លាស់ប្តូរទៅថាមពលព្រះអាទិត្យដែលទទួលបានមូលនិធិពីសហភាពអឺរ៉ុបតាមរយៈកម្មវិធី SWITCH-Asia និងសាធារណរដ្ឋឆែកតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍ឆែក (CzDA)។

ព្រឹត្តិការណ៍នេះនឹងប្រព្រឹត្តទៅចាប់ពី ថ្ងៃទី១៦ ដល់ ថ្ងៃទី២៣ ខែវិច្ឆិកា ដោយក្នុងនោះរួមមានកម្មវិធីដូចជា៖ កិច្ចពិភាក្សា សិក្ខាសាលា ការតាំងពិព័រណ៍ និងកម្មវិធីលើកកម្ពស់ការយល់ដឹង ដើម្បីបង្ហាញពីការច្នៃប្រឌិត ភាពជោគជ័យ និងអត្ថប្រយោជន៍ប្រកបដោយបរិយាបន្ននៃថាមពលស្អាត។ កម្មវិធីនេះក៏នឹងជំរុញកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធក្នុងវិស័យឯកជន វិស័យសាធារណៈ និងការយល់ដឹងក្នុងចំណោមសាធារណជន។

**អំពី EnergyLab Cambodia**

EnergyLab Cambodia គឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលមានគោលដៅបង្កើនបរិមាណថាមពលស្អាតនៅកម្ពុជា ព្រមទាំងជួយជម្រុញឲ្យកម្ពុជាអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឆ្នាំ ២០៣០ របស់ខ្លួនក្លាយជាប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់។

សម្រាប់ព័ត៌មានបន្ថែម និងការចុះឈ្មោះ សូមចូលទៅកាន់គេហទំព័រ៖

https://cleanenergycambodia.org/cleanenergyweek

## សម្រាប់ការសាកសួរព័ត៌មាន សូមទាក់ទង៖


- ស្ថានទូតអូស្ត្រាលី៖ Media.Cambodia@dfat.gov.au
- UNDP: អាត់ ឈុនមួយ អ្នកជំនាញផ្នែកទំនាក់ទំនង នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជា, chhunmuoy.ath@undp.org | 077 872 533
- EnergyLab Cambodia: កញ្ញា ញាណ វិភាវី, ប្រធានផ្នែកទំនាក់ទំនង - vipheavy@energylab.asia | 010936357
- CAPRED: លោក ឃុត ស៊ននិមល, ប្រធានគ្រប់គ្រងផ្នែកទំនាក់ទំនងជាន់ខ្ពស់ - sornnimul.khut@capred.org | 092563474